# ប្រវត្តិ

# រឿងកូរសមុទ្រទឹកដោះ



ចងក្រងដោយ

សុន តុលា

និស្សិតច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

ឆ្នាំ ២០១៦



# ប្រវត្តិ
# រឿងកូរសមុទ្រទឹកដោះ

ចងក្រងដោយ
សុន តុលា
និស្សិតច្បាប់នៃសាលកាវិទ្យាល័យជាតិគ្រប់គ្រង

ឆ្នាំ ២០១៦

# ប្រវត្តិរឿងកូរសមុទ្រទឹកដោះ

## 1) តបៈដើម្បីសំជីវិនមន្ត្រ:

នៅពេលនោះ ក្នុងនាមជាស្តេចនៃ**ពួកទានព** ដែលប្រឆាំងនឹង**ពួកទេវលោក មហាពលី** បានចាញ់សង្គ្រាម ហើយរត់ទៅពឹង **សុក្រឆរ្យៈ** [1] ដែលធ្លាប់ត្រូវ**ព្រះឥន្ទ្រ** និងបក្សពួកប្រមាថមើលងាយ។ **សុក្រចរិយា** ក៏យល់ព្រមចងសម្ព័ន្ធមិត្រជាមួយ**ពួកទានព**។ **កាលកេតុ**ក៏ធ្វើសង្គ្រាមនឹង**ព្រះឥន្ទ្រ** តែពេលនោះ **កាលកេតុ**ចាញ់សង្គ្រាម។ **ព្រះឥន្ទ្រ**ក៏ទទួលបានជ័យជម្នះ ហើយមានអំនួតនឹងខ្លួនឯងជាខ្លាំង។

មានកាលមួយនោះ**ព្រះឥន្ទ្រ** បានជិះ**ដំរីឰរាវ័ត**កាត់អ្នកសច្ចំម្នាក់ ឈ្មោះថា **ទុរពាស**។ **ទុរពាស** បានជូនកម្រងផ្កាពិសេសមួយដល់**ព្រះឥន្ទ្រ**។ **ព្រះឥន្ទ្រ** ក៏ទទួលយកកម្រងផ្ការបស់**ទុរពាស** តែ**ព្រះឥន្ទ្រ**យកទៅដាក់នៅលើប្រមោយដំរី។ ដំរីមិនអាចទ្រាំនឹងក្លិនផ្កានោះបានក៏គ្រវាត់កម្រងផ្កាចោលទៅលើដី។ អ្នកសច្ចំនោះក៏ខឹងយ៉ាងខ្លាំង ព្រោះថាកម្រងផ្កាជាគ្រឿងសិរីសួស្តី គួរតែគេគោរពដូចជាប្រាសាទ។ **សច្ចំទុរពាស** ក៏ជេរដាក់បណ្តាសា**ព្រះឥន្ទ្រ** ឲ្យវលាយអស់សីលមហិទ្ធិរិទ្ធទាំងឡាយ។



ព្រះឥន្ទ្រគង់លើដំរីឰរាវ័ត រូបចម្លាក់នៅប្រាសាទបន្ទាយស្រី

**កាលកេតុ** និង**មហាពលី** រួមគ្នានឹង **សុក្រឆរ្យ:** ធ្វើសង្គ្រាមនឹង**ព្រះឥន្ទ្រ**។ **សុក្រឆរ្យ:** រត់ទៅពឹង**ព្រះសិវ:** សុំ **សំជីវិនមន្ត្រ** ដែលអាចប្រស់អ្នកស្លាប់ឲ្យរស់វិញបាន។ **ព្រះឥន្ទ្រ**ក៏ទៅសុំ**មន្ត្រ:**នេះពី**ព្រះសិវ:**ដែរ។ **សុក្រឆរ្យ:** ត្រូវ**ព្រះសិវ:**ប្រាប់ឲ្យធ្វើ**តប:** រយៈពេលមួយឆ្នាំ ដោយអត់អាហារ ដាំក្បាលចុះក្រោម ទើបអាចទទួលនូវមន្ត្រនេះបាន។ **ព្រះឥន្ទ្រ**គិតថាខ្លួនមិនអាចធ្វើបាន។

**កាលកេតុ** និង**មហាពលី** ក៏សុំ**សុក្រឆរ្យ:** លះបង់នូវតប:នេះ ព្រោះអាចធ្វើឲ្យគាត់គ្រោះថ្នាក់ដល់ជីវិតបាន តែ**សុក្រចរិយា**មិនស្តាប់តាមអ្នកទាំងពីរនាក់នេះឡើយ។ គាត់បានព្យួរខ្លួនគាត់លើដើមឈើមួយដើម ដោយដាំក្បាលចុះក្រោម ហើយនៅពីក្រោមគាត់បានដុតមែកឈើចាស់បង្កើតជាផ្សែង ដែលហុយមកកាត់មុខរបស់គាត់។ **ព្រះម៉ែធរណី** និយាយថា៖ "មានតែអ្នកដែលអាចប្រឈមនឹងការសាកល្បងបានតែប៉ុណ្ណោះ ដែលអាចប្រឈមនឹងជ័យជម្នះបាន។"

**ព្រះវិស្ណុ**បានកោតសរសើរ**សុក្រឆរ្យ:**ជាខ្លាំង ព្រោះតែក្តីតាំងចិត្តរបស់គាត់ ហើយបរិមាណនៃទម្ងន់ការងារ ដែលគាត់បានធ្វើ ដើម្បីសម្រេចអ្វីដែលគាត់ចង់បាន។

**នរទ:** ក៏ទៅជួបនឹង**ព្រះឥន្ទ្រ** ដែលកំពុងតែជឿជាក់ថា **សុក្រឆរ្យ:**ប្រាកដជាមិនអាចសម្រេចតាមប្រាថ្នាឡើយ ហើយប្រាប់**ព្រះឥន្ទ្រ** ថា **សុក្រឆរ្យ:** ប្រាកដជាបានសម្រេចតាមប្រាថ្នា។ ពេលនោះ**ព្រះឥន្ទ្រ**មានការភិតភ័យ។ **នរទ:** ក៏ទៅជួបនឹង**នាងលក្ស្មី** ហើយប្រាប់ថា៖ "រឿងខ្លះបើទោះជាមិនមែនជារឿងពិត តែជារឿងដែលល្អនឹងស្តាប់ រឿងខ្លះបើទោះជារឿងពិត ក៏នៅតែជារឿងមិនគួរស្តាប់។"

ម្តាយរបស់**សុក្រឆរ្យ:**ក៏ទៅជួបនឹង**សុក្រឆរ្យ:** ហើយនិយាយលើកទឹកចិត្តកូនរបស់គាត់។ **ព្រះវិស្ណុ**ឃើញបែបនេះ ទ្រង់មានការកោតសរសើរ ដោយទ្រង់ចាត់ទុកថា ទំនាក់

ទំនងម្តាយ និងកូន ជាគ្រឿងដែលគួរជាទីពេញចិត្តបំផុត និងគ្រប់គ្រាន់បំផុត។ ទ្រង់ក៏នមស្ការអស់អ្នកម្តាយបែបនេះ ព្រោះពួកគេចេះចែករំលែកនូវទុក្ខជាមួយកូនៗ។

**ព្រះឥន្ទ្រ** ឆ្លេឆ្លា ក៏ពឹងស្រីអប្សរាបីនាក់ទៅជួបនឹង **សុក្រឆវ្យៈ** ដើម្បីរំខានតបៈរបស់គាត់។ តែពួកទេពអប្សរបដិសេធ ដោយចាញ់បារមីរបស់**សុក្រចរិយា**។ នៅពេលនោះ **កូនស្រីរបស់ព្រះឥន្ទ្រ** ទ្រង់នាម **ជ័យន្ទី** ចេញមកហើយនិយាយថា៖

"ស្ត្រីមិនគួរយកមកធ្វើប្រើ ដូចជាភាពទន់ខ្សោយរបស់បុរសទេ ព្រោះស្ត្រីនៅទីនេះ ដើម្បីជាកម្លាំងចិត្តរបស់បុរសទៅវិញ។ ស្ត្រីមិនមែនសម្រាប់តែកាមតណ្ហាតែមួយមុខប៉ុណ្ណោះ។ ស្ត្រីត្រូវបានបង្កើតមក ដើម្បីទាក់ទាញការចាប់អារម្មណ៍របស់បុរស ដើម្បីបង្កើតនូវចំណងស្នេហារវាងបុរស និងនារី ហើយគឺដោយសារហេតុផលនេះហើយ ដែលស្ត្រីត្រូវធ្វើខ្លួនជាអប្សរា។"

តែទោះយ៉ាងណា នាងក៏ស្ម័គ្រខ្លួន ដើម្បីទៅរំខានពិធីតបៈរបស់**សុក្រឆវ្យៈ**។ **នាងលក្ស្មី** មានសេចក្តីតានតឹងក្នុងចិត្ត ត្បិតឆាកល្ខោនរបស់**នាងជ័យន្ទី** ហាក់ដូចជាមិនមានប្រយោជន៍អ្វីទាំងអស់ ព្រោះនាងមិនអាចធ្វើបានសម្រេចទេ។ **ព្រះវិស្ណុ**និយាយថា៖ "វាពិបាកណាស់ ដែលនឹងកំណត់ពីជ័យជម្នះ និងបរាជ័យ ព្រោះពេលខ្លះ អ្នកខ្លះឈ្នះដោយសុខចិត្តចាញ់ អ្នកខ្លះចាញ់ព្រោះតែឈ្នះ។"

**ជ័យន្ទី**ទៅជិត**សុក្រឆវ្យៈ** ដោយបន្លំខ្លួនធ្វើជាមានបំណងល្អ។ តែតាមពិតនាងបានដាក់ម្ទេស ក្នុងគំនរឧសដែលដុតបង្ហុយ ដែលធ្វើឲ្យផ្សែងកាន់តែហ៊ីរឡើង មិនអាចដកដង្ហើមបាន ឬក៏ទៅក្បែរបាន។ **សុក្រឆវ្យៈ**ពិបាកទ្រាំជាខ្លាំង តែនៅតែព្យាយាមតាំងខ្លួនក្បាលចុះក្រោម។ នេះជាបទឧក្រិដ្ឋ ដែល**នាងជ័យន្ទី**បានប្រព្រឹត្ត ដែលនាងគួរតែទទួលផលអាក្រក់វិញ នៅពេលក្រោយមកទៀត។

ផ្សែងដែលមានក្លិនហឹរ ក្តៅ មិនអាចដកដង្ហើមបានបន្តហុយទ្រលោម។ **សុក្រឆវ្យៈ** បន្តរងនូវទុក្ខវេទនា។ បន្តិចក្រោយមក គាត់ក៏ចេញឈាមតាមច្រមុះ មាត់ និងភ្នែក។ **ជ័យន្តី** ភ័យស្លន់ស្លោចំពោះទង្វើរបស់ខ្លួន។ នាងក៏ព្យាយាមពន្លត់ភ្លើងនោះវិញ ប៉ុន្តែ**មហាពលី** និង**កាលកេតុ** បានចាប់នាងបោះចេញពីទីនោះ រួចពួកគេក៏ព្យាយាមពន្លត់ភ្លើងនោះ តែត្រូវ**សុក្រឆវ្យៈ**ហាមប្រាម។ **ជ័យន្តី**កើតទុក្ខ។ នាងស្គាល់ពីទង្វើឆ្កួតលីលារបស់ខ្លួន ហើយស្តាយក្រោយ ហើយអង្វរ**ព្រះសិវៈ**ឲ្យជួយសង្គ្រោះ**សុក្រឆវ្យៈ**។

**ព្រះសីវៈ**ក៏បានសង្គ្រោះ**សុក្រឆវ្យៈ**ភ្លាមៗ ហើយបង្គាប់ឲ្យ**សុក្រឆវ្យៈ**ឈប់ធ្វើតបៈបន្តទៀត ព្រោះទ្រង់សម្រេចចិត្តថា **សុក្រឆវ្យៈ** ជាអ្នកដែលគួរទទួលនូវសំជីវិនមន្ត្រនេះ ដោយ**ព្រះឥន្ទ្រ**ប្រើមធ្យោបាយមិនយុត្តិធម៌។ ដូច្នេះ **ព្រះសីវៈ**ក៏ប្រគល់សំជីវិនមន្ត្រដល់**សុក្រឆវ្យៈ**។ **សុក្រឆវ្យៈ**មានសេចក្តីត្រេកអរជាខ្លាំង។ វាក៏សម្លាប់**មហាពលី** រួចក៏ប្រស់ឲ្យរស់ឡើងវិញ ដោយប្រើសំជីវិនមន្ត្រ ដើម្បីជាការល្បងមើល។

ក្នុងពេលប្រារព្ធនូវជ័យជម្នះរបស់គាត់ **ជ័យន្តី** បានសុំទោស**សុក្រឆវ្យៈ** ដោយសុំតាមបម្រើគាត់មួយជីវិត សុខចិត្តធ្វើជាភរិយារបស់គាត់ ដោយសារតែបទឧក្រិដ្ឋ ដែលនាងបានធ្វើដាក់គាត់ ដើម្បីឲ្យនាងអស់ចិត្ត និងស្ងប់ចិត្តដោយសារតែកំហុសរបស់ខ្លួន។ **សុក្រឆវ្យៈ**ស្រឡាំងកាំង។ តើបុត្រីទេវមករៀបការនឹងទានពយ៉ាងម៉េចនឹងកើត? **ជ័យន្តី** និយាយថា វាដូចគ្នានឹងបុរសម្នាក់ រៀបការនឹងស្ត្រីម្នាក់ជាធម្មតាតែប៉ុណ្ណោះ។ នាងអង្វរឲ្យ**សុក្រឆវ្យៈ**យល់ព្រម។

**សុក្រឆវ្យៈ**វង្វេងស្មុំង។ គាត់ប្រាប់នាងពីឋានៈរបស់នាង ហើយប្រាប់ពីគម្រោងការរបស់គាត់ ក្នុងការធ្វើសង្គ្រាមនឹងបិតារបស់នាង ហើយថាគោលបំណងរបស់នាង គឺការរំខានដល់តបៈរបស់គាត់នោះ គ្រាន់តែជាលទ្ធនៃសេចក្តីស្នេហារវាងឪពុក និងកូនតែប៉ុណ្ណោះ វាមិនមែនជាបទឧក្រិដ្ឋអីធ្ងន់ធ្ងរនោះទេ ហើយថានាងអាចចាកចេញត្រឡប់ទៅ

វិញ ដោយមិនបាច់ទទួលទោសអ្វីទាំងអស់។ តែ**នាងជ័យន្តី**មិនកែប្រែសេចក្តីសម្រេចចិត្តឡើយ។ **សុក្រឆរ្យៈ**ក៏យល់ស្របតាមនាង។

**ព្រះឥន្ទ្រ**ស្ទាក់ស្ទើរកាំងដោយកូនស្រីរបស់ខ្លួនរៀបការនឹងទានពម្នាក់។ ប៉ុន្តែមហេសីព្រះឥន្ទ្រជំទាស់នឹង**ព្រះឥន្ទ្រ** ព្រោះ**ព្រះឥន្ទ្រ**ខ្លួនឯងក៏រៀបការនឹងបុត្រីទានពដែរ (ខ្លួននាង) ដូច្នេះគ្មានអ្វីចោទទេ ដែលទានពម្នាក់រៀបការនឹងបុត្រីទេវនោះ។ **ព្រះឥន្ទ្រ**ក៏ដាក់មុខចុះ។

**សុក្រឆរ្យៈ**ក៏ប្រកាសសង្គ្រាម។ **ព្រះឥន្ទ្រ**ក៏ប្រកាសសង្គ្រាម។ **ជ័យន្តី** ជាអ្នកចាញ់ បើទោះជាខាងណាចាញ់ក៏ដោយ។ ដូច្នេះនាងក៏ស្នើសុំសេចក្តីសម្របសម្រួល តែ**សុក្រឆរ្យៈ**បដិសេធ។ ដូច្នេះនាងក៏ឈរនៅខាងគាត់ ដោយនាងជាភរិយារបស់គាត់ ដែលជាទីមួយសមគួរជាងឪពុកនាង។ សង្គ្រាមក៏ចាប់ផ្តើម។ រាល់លើក ពេលដែលទ័ពរបស់**ព្រះឥន្ទ្រ**សម្លាប់ពួកទានពបានម្នាក់ **សុក្រឆរ្យៈ** ប្រោះឲ្យរស់ឡើងវិញ ដោយប្រើសំជីវិនមន្ត្រ។

ភ្លើងសង្គ្រាមក៏ឆេះសន្ធោសន្ធៅឡើង។ **ព្រះឥន្ទ្រ**មើលឃើញ បរាជ័យរបស់ខ្លួន ក៏រត់គេចខ្លួនជាមួយនឹងទាហានរបស់ខ្លួន។ ពួកទានពប្រារព្ធពិធីជ័យជម្នះ។ **ព្រះឥន្ទ្រ** និងបក្សពួក ព្រួយបារម្ភពីដំណោះស្រាយតទល់នឹងសំជីវិនមន្ត្រ។ ដូច្នេះ **ព្រះឥន្ទ្រ** និងបរិវារក៏ទៅពឹងពាក់**ព្រះវិស្ណុ** ដែលនៅពេលនោះ **ព្រះវិស្ណុ**ប្រាប់ថាដំណោះស្រាយតបនឹងសំជីវិនមន្ត្រគឺ **ទឹកអម្រឹត**។

[1] ជាគ្រូសង្គ្រាមរបស់ពួកអសុរៈ។ **សុក្រឆរ្យៈ** ជាអាទិទេពសង្គ្រាម ប៉ុន្តែជាអ្នកគាំទ្រពួកអសុរៈ។

## 2) កូរសមុទ្រទឹកដោះដើម្បីទឹកយកអម្រឹត

**សំជីវិនមន្ត្រ**អាចប្រោះឲ្យរស់វិញបាន តែ**ទឹកអម្រឹត**ដែលអាចធ្វើឲ្យមានជីវិតអមតៈមានការព្រួយបារម្ភតិច និងសប្បាយច្រើន។ ក៏ប៉ុន្តែដើម្បីទទួលបានទឹកអម្រឹត គេត្រូវកូរសមុទ្រ ដូចកូរទឹកដោះបានមកជាប៊័រ។ ដើម្បីកូរទឹកសមុទ្រ គេត្រូវការជ្រលងធំមួយ បើគ្រាន់តែទឹកដោះគេត្រូវការដៃពីរ នោះដើម្បីកូរទឹកសមុទ្រ គេត្រូវការក្រុមធំៗពីរ។ ដូច្នេះ

**ព្រះវិស្ណុ** ស្នើឲ្យ**ព្រះឥន្ទ្រ**ចងសម្ព័ន្ធភាពនឹងពួកទានព ដើម្បីបង្កើតជាក្រុម តែ**ព្រះវិស្ណុ**ធានាថា ពួកទានពនឹងមិនអាចទទួលបានទឹកអម្រឹតនោះទេ។

ដូច្នេះ**ព្រះឥន្ទ្រ**ក៏ទៅជួបនឹងពួកទានព ដើម្បីសុំជំនួយកូរសមុទ្រយកទឹកអម្រឹត។ **សុក្រឆរ្យ:** សង្ស័យ ហើយបញ្ចេញហេតុផលថា ភ្លើង និងទឹកមិនអាចធ្វើការជាមួយគ្នាបានទេ។ ប៉ុន្តែពេលដែល**ព្រះឥន្ទ្រ**សួរថា បើ**សុក្រឆរ្យ:**ខ្លួនឯងស្លាប់ តើបាននរណាប្រោះឲ្យរស់ឡើងវិញ។ **សុក្រឆរ្យ:**និយាយមិនចេញ។

បើទោះជា**សុក្រឆរ្យ:**សង្ស័យពីល្បិចកល គាត់ដឹងច្បាស់ថា បើគាត់ស្លាប់ពួកទានពទាំងអស់ក៏នឹងស្លាប់ដែរ។ ដូច្នេះ ក៏យល់ព្រមកូរទឹកសមុទ្រយកទឹកអម្រឹត ជាមួយនឹងពួកទេវលោក។ **ព្រះវិស្ណុ**ពេញចិត្តនឹងវិធីរបស់**ព្រះឥន្ទ្រ** ដែលអាចជម្នះ**សុក្រឆរ្យ:**ឲ្យចូលរួមកូរសមុទ្រយកទឹកអម្រឹតបាន។

**ព្រះវិស្ណុ**ក៏ហៅ**បក្សីរាជ**មកគាល់ ហើយសុំឲ្យ**បក្សីរាជ**ជញ្ជូន**ភ្នំមន្ទរ:**។ **បក្សីរាជ** ក៏ធ្វើដំណើរទៅជាមួយ**ស្ដេចពស់វសុកិ**។ នៅពេលដែលពួកគេទៅដល់**ភ្នំមន្ទរ: វសុកិ**ក៏រុំព័ទ្ធភ្នំរួចហើយ**បក្សីរាជ**ក៏ហោះយោងភ្នំនោះ បន្ទាប់ពី**សុតារស៍នចក្រ**របស់**ព្រះវិស្ណុ**បានកាត់ផ្ដាច់ភ្នំនោះរួចមក។ **បក្សីរាជ** និង**វសុកិ**បានយកភ្នំនោះមកដាក់នៅមាត់សមុទ្រ ដែលពួកទានព និងទេវតាកំពុងតែរង់ចាំ។

**វិស្ណុ**ក៏ហៅ**នរទ** មកជួយដោះស្រាយបញ្ហាបន្តិចបន្តួច។ នៅពេលកូរសមុទ្រ ភ្លើងបានកើតចេញពីមាត់របស់**វសុកិ** ដូច្នេះគេត្រូវប្រុងប្រយ័ត្នពេលកាន់**វសុកិ** នៅពេលនោះទេវតាមិនមែនជាអ្នកកាន់ខាងក្បាលទេ។ **នរទ**ធានាចំពោះមុខ**ព្រះវិស្ណុ**ថា គាត់នឹងទទួលខុសត្រូវលើបញ្ហានេះ។ ប្រាកដណាស់ នៅលើមាត់ឆ្នេរជម្លោះបានកើតឡើង ដោយសារតែរឿងខាងណាត្រូវនៅខាងក្បាល ខាងណាត្រូវនៅខាងកន្ទុយពស់។

**នរទ**ប្រាប់ថា អ្នកដែលខ្លាំងជាងគេ ត្រូវនៅខាងក្បាល។ គាត់និយាយប្រាប់ពួកទានពថា ពួកទេវតាជាអ្នកខ្លាំងជាង។ ប៉ុន្តែពួកទានពនិយាយថា ក្នុងសង្គ្រាមលើកក្រោយបង្អស់ គឺពួកទានពដែលជាអ្នកឈ្នះ មិនមែនពួកទេវតាទេ ដូច្នេះពួកគេជាអ្នកខ្លាំងពូកែជាង។ ដូច្នេះ**នរទ**ក៏យល់ព្រម ហើយបង្គាប់ពួកទេវតាឲ្យកាន់ខាងកន្ទុយ រីឯពួកទានពកាន់ខាងក្បាល។ ពួកទេវតាក៏យល់ព្រម។

**សុក្រឆរ្យ:**ខឹងយ៉ាងខ្លាំង។ គាត់ស្គាល់អំពីភ្លើង។ ដូច្នេះគាត់ក៏បន្ទោសខ្លួនឯង ដែលមិនបាននៅកន្លែងពេលនោះ ហើយបន្ទោសពួកទានព ដែលល្ងង់ខ្លៅចាញ់បោក ការបញ្ឆោរពី**នរទ**។ ប៉ុន្តែពួកទានពបានសម្រេចចិត្តរួចស្រេចទៅហើយ មិនអាចកែប្រែវិញបានឡើយ។ ដូច្នេះ **សុក្រឆរ្យ:**ក៏បញ្ជូនគ្នាគាត់ម្នាក់ ទៅបន្លំនឹងពួកទេវតា ដើម្បីកុំឲ្យចាញ់បោកពួកទេវតាទៀត។

អ្វីៗគ្រប់យ៉ាងបានរៀបចំជាស្រេច **ព្រះឥន្ទ្រ**ក៏សុំឲ្យ**បក្សីរាជ** លើក**ភ្នំមន្ទរ:**មកដាក់ក្នុងសមុទ្រ ដើម្បីឲ្យពួកគេកូរសមុទ្រ។ **បក្សីរាជ**ដោយមាន**វសុកិ**ជាជំនួយ បានលើក**ភ្នំមន្ទរ:** មកដាក់ក្នុងសមុទ្រ តែដោយសារសមុទ្រជ្រៅពេក ភ្នំក៏លិចចូលក្នុងសមុទ្រ។ ពួកគេមិនអាចកូរទឹកសមុទ្របាន បើភ្នំនេះមិនអាចដាក់ក្នុងសមុទ្រដោយមិនលិចបានទេ។



ពួកទានពព្រមានថា នឹងលះបង់បេសកម្មដែលមិនអាចនេះ។ **ព្រះឥន្ទ្រ**និយាយថា បញ្ហានេះអាចដោះស្រាយបាន នៅពេលដែលគេត្រូវការវត្ថុធំសម្បើម ដូចជាទឹកអម្រឹតនោះ។ គាត់ និងពួកទេវតា បានហៅ**ព្រះវិស្ណុ**ជួយដោះស្រាយបញ្ហានេះ។

### 3) អវតារកូម៌

**ព្រះវិស្ណុ**ប្រាប់**នាងលក្ស្មី**ថា ទ្រង់ត្រូវយាងចេញទៅផែនដី។ តែ**នាងលក្ស្មី**រំឭកថា ទ្រង់គួរតែធ្វើបែបនេះ តែនៅពេលដែលពួកមាណព (មនុស្ស) មានគ្រោះថ្នាក់តែប៉ុណ្ណោះ។ **ព្រះវិស្ណុ**ក៏ពន្យល់ថា បើសិនជាពួកទានពឈ្នះ នោះវាច្បាស់ជាមានគ្រោះថ្នាក់ដល់ពួកមាណពមិនខាន ដើម្បីកុំឲ្យរឿងបែបនេះកើតឡើងបាន ទ្រង់ត្រូវតែយាងចេញទៅ។ នាងក៏សួរថា ចុះនាងវិញ?។ នាងមិនអាចរស់នៅបែកគ្នាពី**ព្រះវិស្ណុ**បានទេ។

**ព្រះវិស្ណុ**បានថា៖ "ការវិលមកជួបគ្នាវិញ បន្ទាប់ពីបែកគ្នា ជារឿងដែលគួរឲ្យរំភើបបំផុត ការជួបគ្នាលើកនេះពិតជាមហាអស្ចារ្យណាស់។" គាត់និយាយថា៖ "ទោះបីជានាងលេចមកជាមួយ ដោយការកូរសមុទ្រទឹកដោះ សម្រាប់គាត់ នាងមានតម្លៃជាងទឹកអម្រឹតទៅទៀត ព្រោះទឹកអម្រឹតសម្រាប់ទេវតា រីឯនាងវិញ នាងពោរពេញទៅដោយសេចក្ដីស្រឡាញ់ និងជាម្ដាយនៃសេចក្ដីស្រឡាញ់ ជាវត្ថុតែមួយគត់ ដែលឧបត្ថម្ភលោកនេះឲ្យនៅតែមួយ។" ដូច្នេះទ្រង់ក៏កោតសរសើរនាង ដែលមានលក្ខណៈយ៉ាងដូច្នេះ ហើយសុំឲ្យនាងទុកចិត្តលើទ្រង់ពេលដែលទ្រង់ចុះទៅផែនដីជាអណ្ដើក។ ដូច្នេះអវតាជា**អណ្ដើកកូម៌**ក៏ចាប់ផ្ដើម។

**វិស្ណុ**ជាអណ្ដើកប្រាប់**ព្រះឥន្ទ្រ**ថា គាត់នឹងជួយទ្រ**ភ្នំមន្ទរៈ** លើខ្នងក្រោមសមុទ្រ នៅពេលដែលកូរវឹកទឹកសមុទ្រនោះ។ អ្នកទាំងអស់គ្នាសប្បាយរីករាយ។ អណ្ដើកក៏បំពេញតួនាទីរបស់ខ្លួន។ ក្បាល**វសុកិ**បានមកខាងពួកទានព។ ខាងកន្ទុយបានទៅពួកទេវតា។

### 4) នីលកណ្ឋ

ទឹកអម្រឹតនេះជាអ្វី ដែលពួកគេចង់បាន។ ប៉ុន្តែការពិតបានលេចឡើង។ គឺ**ថ្នាំពុលកាលកូដ** [1]។ ភាពច្របូលច្របល់បានកើតឡើង។ គ្រប់គ្នាមានពួកទានព ទេវតា និងមនុស្សភ័យស្លន់ស្លោ រត់ប្រាសអាយុគេចចេញពីថ្នាំពុលនេះឲ្យបានឆ្ងាយបំផុត។

ទានពក៏ទៅជួបនឹង**សុក្រឆរ្យៈ** ហើយសុំផ្អាកការកូរសមុទ្រទឹកដោះ។ **សុក្រឆរ្យៈ** ប្រាប់កុំឲ្យខ្លាច ព្រោះគាត់អាចប្រោះអ្នកស្លាប់ឲ្យរស់វិញបាន ហើយកើតក្ដីសង្ស័យចំពោះពួកទេវតា។ ទេវតាក៏ទៅជួបនឹង**ព្រះវិស្ណុ** ហើយនិយាយទូលពិតថា៖ "តើរឿងចង្រៃស្អីគេហ្នឹងព្រះអង្គ?"

**ព្រះវិស្ណុ**ក៏តបថា បើការស្វែងរកទឹកអម្រឹតវាជាការងាយស្រួល តើមានន័យអីទៅ? ឆាកល្ខោនជីវិត គឺជាការលេងបិទពួនជាមួយនឹងសេចក្ដីស្លាប់។ គេត្រូវតែចេះប្រថុយប្រថាន។ ឧទាហរណ៍ដូច ទារក និងម្ដាយស្ទើរគ្រោះថ្នាក់ដល់ជីវិត ក្នុងដំណើរការរយៈកាលប្រាំបួនខែ ហើយនៅកើតចេញមក លោកទាំងមូលញញឹមដាក់។ ដូច្នេះ ទឹកអម្រឹត មិនមែនជាការងាយស្រួលនោះទេ។ នៅពេលនោះ **ព្រះវិស្ណុ**យករាងកាយជាមនុស្ស ដែលនៅពេលជាមួយគ្នា អវតាររបស់ព្រះអង្គជា**អណ្ដើកកូម៌**។

ដូច្នេះ**ព្រហ្មា** ក៏សួរ**ព្រះវិស្ណុ**ពីសុវត្ថិភាពរបស់ភាវៈ ដែលទ្រង់បានបង្កើត គឺពួកមនុស្ស ចំពោះមុខ**ថ្នាំពុលកាលកូដ** នេះ។ **ព្រះវិស្ណុ**ក៏អល់អែក។ ជាចុងក្រោយពួកគេ ក៏ទៅពឹង**ព្រះសិវៈ** **ព្រះសិវៈ**ក៏ធានាថានឹងជួយដោះស្រាយវិបត្តិនេះ។

**ព្រះសិវៈ**សប្បាយរីករាយ ដោយឃើញ**ព្រហ្មា** និង**ព្រះវិស្ណុ** ព្រមទាំងពួកទេវតាផងដែរ។ ទ្រង់ស្វាគមន៍ពួកគេយ៉ាងសមរម្យ។ **ព្រះសិវៈ**មានបន្ទូលប្រាប់ កុំឲ្យពួកគេមានសេចក្ដីភ័យខ្លាចអី។ ពួកគេទាំងអស់គ្នាក៏ចុះទៅសមុទ្រ។ **ព្រះសិវៈ**សុខចិត្តលេបថ្នាំពុលកាលកូដ នោះទាំងអស់ រួចហើយក៏បោះថូរទទេនោះចោល។

**ព្រះវិស្ណុ**ទ្រង់កោតសរសើរ**ព្រះសិវៈ**ជាខ្លាំង ដែលបានសង្គ្រោះលោក។ ទ្រង់គោរព**ព្រះសិវៈ** ហើយហៅ**ព្រះសិវៈ**ថា **នីលកណ្ឋ** មានន័យថា អ្នកមានកខៀវ ដោយ**ព្រះសិវៈ** បានបញ្ឈប់ថ្នាំពុលនោះត្រឹមបំពង់ក ធ្វើឲ្យករបស់ទ្រង់ក្លាយជាខៀវ។ **ព្រាហ្មា**ក៏សម្ដែងសេចក្ដីអរគុណដែរ ព្រោះថាពួកទានពមាន**សុក្រឆរ្យៈ** ពួកទេវតាមាន**ព្រះវិស្ណុ** តែ

សម្រាប់ពួកមនុស្ស **ព្រះវិស្ណុ**ជាអ្នកទទួលខុសត្រូវ ហើយមានតែ**ព្រះសិវៈ**មួយអង្គគត់ ដែលអាចសង្គ្រោះពួកគេបាន។

**ព្រះសិវៈ**ក៏ពន្យល់ពីភាពចាំបាច់នៃថ្នាំបំពុល។ នៅទីណាមានអម្រឹត នៅទីនោះត្រូវតែមានថ្នាំពុល។ ថ្នាំបំពុលមិនអាចលុបបំបាត់ទាំងស្រុងបានទេ តែឥទ្ធិពលរបស់វាអាចកាត់បន្ថយបាន។ ជាម្តងទៀត**ព្រះវិស្ណុ** សម្តែងក្តីពេញចិត្តដល់**ព្រះសិវៈ**។ តែព្រះអង្គផ្តន្ទាអ្នកដែលបានបំពុលទឹក ដោយបោះវត្ថុមិនល្អចូលក្នុងសមុទ្រ ដែលក្លាយទៅជាថ្នាំពុល ដែលមានផលមិនល្អដល់សត្វក្នុងទឹក។

**ព្រះឥន្ទ្រ**ក៏ទៅជួបនឹង**សុក្រឆរ្យៈ** ហើយនិយាយប្រាប់ថា ថ្នាំពុលកាលកូដត្រូវបានបញ្ចប់ហើយ។ **សុក្រឆរ្យៈ**សន្និដ្ឋានថា មានតែ**ព្រះសិវៈ**មួយអង្គគត់ ដែលអាចបញ្ឈប់រឿងនេះបាន។ **ព្រះឥន្ទ្រ**ក៏ស្នើ**សុក្រឆរ្យៈ** ឲ្យបញ្ជូនបរិវាររបស់ខ្លួនត្រឡប់ទៅវិញ ដើម្បីបំពេញការងារឡើងវិញ។ ពួកគេមានការស្ទាក់ស្ទើរ តែ**សុក្រឆរ្យៈ**យល់អំពីផលប្រយោជន៍របស់អម្រឹត ដូច្នេះគាត់ប្រាប់ឲ្យគ្នីគ្នារបស់គាត់ចេញទៅ ហើយបញ្ជាឲ្យ**ស្វនិភានុ**ឃ្លាំចាំមើលការងារនេះដូចលើកមុន។

[1] ហៅម្យ៉ាងទៀតថា **ហលាហលៈ**។

## 5) ស្វយំវរៈ

បន្ទាប់ពី**ព្រះសិវៈ**បានលេបថ្នាំពុលរួចហើយ ពួកទេវតា និងពួកអសុរា ក៏ចាប់ផ្តើមកូរទឹកសមុទ្រម្តងទៀត។ វត្ថុដែលផុសចេញពីសមុទ្រ គឺ**មេគោកមធេនុ**។ **ពួកព្រាហ្មណ៍**ទាមទារយកមេគោនេះ ដោយអះអាងថា **ព្រាហ្មណ៍**មានសិទ្ធិយកវត្ថុ ដែលផុសចេញដំបូង។ តែដោយពួកទេវតា និងអសុរា បានលើកអំពីកាលកោត **ព្រាហ្មណ៍**ក៏ហើបមាត់លែងចេញ។ ប៉ុន្តែដោយសារទាំងទេវៈ និងអសុរៈ សុទ្ធតែគោរពបូជាព្រាហ្មណ៍ដូចគ្នា ពួកគេក៏យល់ព្រមឲ្យមេគោនេះដល់**ព្រាហ្មណ៍**។

*វត្ថុដែលផុសចេញបន្ទាប់មកទៀត គឺ**សេះក្បាលប្រាំពីរ**ដ៏ស្អាត ដែលមានឈ្មោះថា **ឧច្ចៃស្រវ័ស**។ **ព្រះឥន្ទ្រ**ត្រូវបាន**ព្រះវិស្ណុ**ប្រាប់កុំឲ្យទារយកសេះនេះ ដូច្នេះគាត់ក៏នៅស្ងៀម។ **ស្តេចអសុរា មហាពលី** ក៏សម្តែងនូវការពេញចិត្តចំពោះសេះនេះ ហើយគេក៏អនុញ្ញាតឲ្យគាត់យកសេះនេះ។ **សេះឧច្ចៃស្រវ័ស**នេះតំណាងឲ្យការលើកតម្កើង ភាពក្រអឺតក្រទម ដែលអាចនាំឲ្យអ្នកស្វែងរកវិជ្ជាប្រាសចាកពីផ្លូវរបស់ខ្លួន។*

*ពួកអសុរៈ និងពួកទេវៈកើតពីឪពុកតែមួយ គឺ**បណ្ឌិត កស្សបៈ** តែម្តាយទីទៃ។ ពួកទេវកើតពី**អទិតិ** មានន័យថា មិនព្រិលភ្នែក មិនស្រវាំងភ្នែក មិនច្រលំភ្នែក។ ឯម្តាយរបស់ពួកអសុរៈគឺ**ទិតិ** មានន័យថា មើលអ្វីច្រើនតែច្រលំ មិនយល់ស៊ីជម្រៅពីវត្ថុដែលឃើញ។*

*វត្ថុផុសចេញបន្ទាប់មកទៀត គឺ**ដំរីឰរាវ័ត** ជាស្តេចដំរីស។ ដោយសារតែពួកអសុរៈបានយកសេះទៅហើយដូច្នេះ ពេលនេះជាវេណរបស់ទេវៈវិញ ដូច្នេះ**ព្រះឥន្ទ្រ**ក៏យកដំរីឯកនេះ ជាជំនិះរបស់គាត់។ ដំរីដែលមានភ្នែកតូចជាងខ្លួនខ្លាំង តំណាងឲ្យសមត្ថភាពមើលឃើញនូវចំនុចសំខាន់នៃវត្ថុនានា។*

*បន្ទាប់មកទៀត ក៏ផុស**គ្រឿងអលង្ការ កោស្តុភា** **ព្រះវិស្ណុ**ក៏យកធ្វើជាគ្រឿងលម្អ។ បន្ទាប់មកទៀត ក៏ផុសចេញ**ដើមឈើបំពេញប្រាថ្នា បរិជាត និងស្រីទេពអប្សរ** ដែលទាំងពីរនេះក្រោយមកក្លាយជាវត្ថុសក្ការរបស់ស្ថានសួគ៌។*

*បន្ទាប់ពីកូរបានច្រើនដងរួចមក ក៏លេចចេញ**ព្រះនាងលក្ស្មី** ដែលស្អាតដូចរាល់ដង។ តែពេលនោះនាងលេចចេញមកជាស្រី។ **កាលកេតុ** រៀបរាប់បបូរមាត់នាង ភ្នែក មុខ មាត់ ចរឹក សក់ ដំណើរ ដោយពាក្យពេចន៍ល្អសព្វបែបយ៉ាង ហើយបានដាស់ឲ្យតណ្ហារបស់ខ្លួនគាត់ស្ទើនឡើង។ **សុក្រឆរ្យៈ**សុំ**ព្រះឥន្ទ្រ**យកនាង។ តែ**ព្រះឥន្ទ្រ**តបថា នាងជាទេពីជាទេពធីតា សម្រាប់ទេវតាមួយអង្គ។ ដូច្នេះ**ព្រះឥន្ទ្រ**បដិសេធ។*

**កាលកេតុ** និងបក្សពួកដើរចេញ ហើយនិយាយថា ពួកគេនឹងធ្វើសង្គ្រាមដើម្បីកំណត់ថានរណាជាអ្នកត្រូវបានស្រីនេះ។ ភាគីទាំងពីរ ក៏ឈប់កូរទឹកសមុទ្រ ហើយទៅលានចម្បាំងប្រយុទ្ធគ្នាដណ្តើមស្រី។

**នាងលក្ស្មី**មានទុក្ខព្រួយ ដោយមិនអាចរក**ព្រះវិស្ណុ**ឃើញ។ អារម្មណ៍នាងស្រែកហៅរកទ្រង់ ភ្នែករបស់នាងសម្លឹងរកទ្រង់ គ្រប់ភាគទាំងអស់នៃកាយនាងត្រូវការទ្រង់។ ដូច្នេះ**ព្រះវិស្ណុ**ក៏មកដល់។ **ព្រះវិស្ណុ** និង**នាងលក្ស្មី**ក៏បានជួបគ្នា ប្រកបដោយក្តីរីករាយឥតឧបមា ប៉ុន្តែ**ព្រះវិស្ណុ** មានកែវភ្នែកប្រកបដោយអាថ៌កំបាំង ប្រាប់**នាងលក្ស្មី** ថា ឥលូវនេះនាងចេញមកពីសមុទ្រ ដូច្នេះនាងជា**សាគរបុត្រី** ដូច្នេះនាងត្រូវទៅជួបអ្នកបង្កើតសមុទ្រ **ព្រហ្មា** ដើម្បីកំណត់ពីវាសនារបស់នាង រួចក៏ទុកនាងចោលតែម្នាក់ឯងទៅ។

ដូច្នេះ**នាងលក្ស្មី** ក៏ទៅជួបនឹង**ព្រហ្មា** ហើយប្រាប់នាងពីតម្រូវការចាំបាច់របស់នាងចំពោះ**ព្រះវិស្ណុ** ហើយប្រាប់អំពីចម្បាំងរវាងពួកទានព និងទេវតា។ **ព្រហ្មា**និយាយថា៖ "អីក៏សំរាមម្ល៉េះ!" ហើយក៏យាងទៅលានសង្គ្រាម។ គាត់ទៅដល់ត្រឹមពេលដែលសង្គ្រាមហៀបនឹងចាប់ផ្តើម ហើយប្រាប់ពួកទេវតា និងពួកទានព អំពីគោលការណ៍របស់ស្រី។ ទ្រង់ប្រាប់ពួកគេអំពីសិទ្ធិរបស់ស្ត្រី ហើយថាស្ត្រីមិនអាចចាត់ទុកដូចជា របស់គ្មានជីវិតបានទេ ដែលគ្មាននរណាអាចយកជាកម្មសិទ្ធិបានទេ។

ដូច្នេះគាត់ក៏ចាប់ផ្តើមពិធីថ្មីមួយ ហៅថា **ស្វយំវរៈ** ដែលក្នុងនោះស្រី ទទួលបានសិទ្ធិផ្តាច់មុខលើបុរស ដែលនាងជ្រើសរើស មានសិទ្ធិក្នុងការជ្រើសរើសបុរស ដែលនាងពេញចិត្ត ហើយមិនអាចបុរសណាមកជ្រើសរើសយកនាងបានឡើយ។

**មហាពលី**និយាយលើក**កាលកេតុ**ថា **កាលកេតុ**ខ្លាំង ដូច្នេះនាងនឹងជ្រើសរើសយកគាត់តែម្នាក់គត់ តែ**កាលកេតុ**បើកភ្នែកធំៗ តែក្នុងចិត្តគិតថាវាមិនអាចរួចជាស្រេចទៅហើយ។ **នាងលក្ស្មី**មានការព្រួយបារម្ភ។ **នរទ**ក៏លេចចេញមក។ គាត់ប្រាប់នាងថា ស្នាមញញឹម

របស់នាង ជាវត្ថុដែលអាចផ្តល់ជីវិតឡើងវិញ ដល់ភាវរស់ជាច្រើន ហើយឥលូវនេះស្នាមញញឹមនោះ ម្តេចក៏ស្លាប់បាត់អញ្ចឹង។ តើអ្វីទៅជាបញ្ហា? នាងក៏តបវិញថា នៅក្នុងពិធីស្វយំវរៈ ដែលនឹងមកដល់នេះ មានតែពួកទេវតា និងទានពប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួម តែ**នារាយណ**របស់នាង មិនអាចមកចូលរួមបានទេ។ តើឲ្យនាងអាចជ្រើសរើសណាផ្សេងទៀតក្រៅពីទ្រង់បាន?

នាងក៏សុំឲ្យ**នរទ**ជួយយ៉ាងណាឲ្យ**នារាយណៈ**មកចូលរួមក្នុងពិធីស្វយំវរៈ។ **នរទៈ**មិនអាចនិយាយអ្វីចេញបាន ដោយ**នារាយណៈ**មិនត្រូវបានគេអញ្ជើញមកចូលរួមក្នុងពិធីនេះទេ។

ស្វយំវរៈក៏ចាប់ផ្តើម។ គ្មានសញ្ញាអំពី**ព្រះវិស្ណុ** នៅក្នុងពិធីនេះទេ។ មានតែពួកទានព និងទេវតាប៉ុណ្ណោះ។ **សាគរបុត្រី** មានចិត្តព្រួយបារម្ភជាខ្លាំង។ នាងរង់ចាំអ្វីមួយ។ **ព្រហ្មា** ជាអ្នករៀបចំពិធី ក៏ប្រកាសបើកពិធីស្វយំវរៈ ជាលើកដំបូងមិនធ្លាប់មាន ជាពិធីមួយដែលស្ត្រីមានសិទ្ធិជ្រើសរើសបុរស ដែលនាងពេញចិត្ត។

**នាងសាគរបុត្រី** នៅតែបារម្ភក្នុងចិត្ត នាងដើរកាត់ហ្វូងទេវតា និងទាណព នាងបដិសេធទាំងអស់ នៅពេលនោះ ភ្នែករបស់នាងសម្លឹងមើលទៅតែទ្វារ សង្ឃឹមថា**ព្រះវិស្ណុ**នឹងចូលមក។ តែគ្មានទេ។ នាងបដិសេធគេគ្រប់គ្នា។ នៅក្នុងចិត្តរបស់នាងបានគិតក្នុងចិត្តថា៖

1. អ្នកខ្លះចេះទ្រាំនឹងការលំបាកបែបយ៉ាង ប៉ុន្តែមិនចេះគ្រប់គ្រងកំហឹងរបស់ខ្លួន (ដូចជា**ឥសីទុរវ័ស**ជាដើម)។
2. អ្នកខ្លះចេះច្រើន តែចូលចិត្តនាំរឿងដាក់ខ្លួន (ដូចជា **សុក្រឆរ្យៈ**នេះជាដើម)។
3. អ្នកខ្លះទៀតឧត្តុង្គឧត្តមណាស់ តែមិនអាចជម្នះលើតណ្ហាបាន (ដូចជា**ព្រះព្រហ្ម**)។
4. អ្នកខ្លះទៀតខ្លាំងពូកែល្បីល្បាញណាស់ (ដូចជា**ព្រះឥន្ទ្រ**នេះ) តែបានប្រយោជន៍អ្វី បើអ្នកនោះនៅតែពឹងគេឲ្យជួយការពារដដែលនោះ។
5. អ្នកខ្លះថ្វីបើហ្មត់ចត់ក្នុងការតាំងធម៌ តែខ្វះក្តីមេត្តា (ដូចជា**បរសុរម**)។

6. អ្នកខ្លះជាប់នឹងពលីកម្ម (ដូចជា**ស្តេចសិពិ**) តែពលីកម្ម មិនគ្រប់គ្រាន់សម្រាប់មុក្តិទេ។
7. អ្នកខ្លះគ្មានញាតិមិត្ត អ្នកនោះនឹងមិនចេះគិតគូរដល់អ្នកដទៃ ដូចជាភរិយាទេ ដូច្នេះមិនអាចមានទំនាក់ទំនងបានទេ។
8. អ្នកខ្លះ (ដូចជា**ឥសីមក្កន្ទេយ**) ដែលមានអាយុវែង តែពួកគេគ្មានអធ្យាស្រ័យល្អ ដែលស្ត្រីពេញចិត្ត។ អ្នកដែលមានអធ្យាស្រ័យល្អ ដែលស្ត្រីពេញចិត្ត តែមានអាយុខ្លីទៅវិញ។
9. អ្នកដែលមានទាំងពីរ (អាយុវែង និងមានអធ្យាស្រ័យល្អ ដូចជា**ព្រះសិវៈ**) បែរជារស់នៅដោយគ្មានរសជាតិទៅវិញ។
10. អ្នកដែលរស់នៅប្រកបដោយរសជាតិផ្អែមល្ហែម ជីវិតអមតៈ និងមានអធ្យាស្រ័យមិនកំណត់ គ្មាននរណាផ្សេងទៀតទេ សម្រាប់ខ្ញុំ (**ព្រះវិស្ណុ**)។

ប៉ុន្តែនៅចុងក្រោយ សល់តែ**កាលកេតុ**ម្នាក់គត់ ដែលនាងមិនអាចបដិសេធបាន។ ដោយគាត់ជាបុរសតែម្នាក់គត់ដែលនៅសល់ នាងត្រូវតែជ្រើសរើសយកគាត់។ នាងរួញរា។ នាងអស់សង្ឃឹម ក្នុងចិត្តច្របូកច្របល់ជាខ្លាំង។

ស្រាប់តែពេលនោះ **ព្រះវិស្ណុ**ក៏ចូលមកដល់មែន។ **លក្ស្មី**ត្រេកអរជាខ្លាំង។ នាងចាប់អារម្មណ៍លើទ្រង់។ នាងរីករាយគ្មានដែនកំណត់។ នាងស្រក់ទឹកភ្នែក នាងរត់ទៅរកទ្រង់ ហើយជ្រើសរើសយកទ្រង់ ជាបុរសរបស់នាង។ ពួកទេវតាកោតស្ញប់ស្ញែងជាខ្លាំង។

ជំនួបរវាង**លក្ស្មី** និង**វិស្ណុ** ក្លាយជាប្រវត្តិមួយ ដូចដែល**ព្រះវិស្ណុ**បានសន្យា។ រំភើប លាយភ័យ តាមតែអាច។ ពួកទាណពអន់ចិត្តជាខ្លាំង ក៏ទៅជួប**សុក្រឆរ្យៈ** សុំឈប់បន្តកូរសមុទ្រទឹកដោះបន្តទៀត។ ប៉ុន្តែ**សុក្រឆរ្យៈ**មិនយល់ស្របតាម។

### 6) <u>*អវតារមោហិនី*</u>

ការកូរទឹកសមុទ្រក៏បន្ត។ បន្ទាប់មកទៀត ក៏ផុសចេញនារីម្នាក់ មានភ្នែកជាផ្កាឈូក នាងគឺ **វរុនី** ជាទេពធីតានៃសុរា។ ពួកអសុរាក៏ចាប់យកនាង។ ជាចុងក្រោយក៏ផុសចេញបុរសម្នាក់មានដៃវែង សាច់ដុំធំ កាន់ថូរមួយដាក់ទឹកអម្រឹត។ អ្នកនោះគ្មាននរណាក្រៅពី **ធន្វន្តរី** [1] ទេ គឺជាអ្នកបង្កើតអាយុរវេទ។ ពួកទេវតា និងទានពជ្រួលច្របល់ជាខ្លាំង។ មានពួកទាណពម្នាក់ ដែលលោភលន់ជាខ្លាំង ក៏ឆក់យកទឹកអម្រឹតរួចរត់ទៅបាត់ទៅ។

ដូច្នេះពួកទេវតា គេក៏ពឹង**ព្រះវិស្ណុ**ម្តងទៀត ដែលពេលនោះ**ព្រះវិស្ណុ**មានព្រះបន្ទូលថា មិនអាចឲ្យពួកទាណពគ្រប់គ្រងលោកបានជាដាច់ខាត។ បើបណ្តោយឲ្យដូច្នេះ រោមនឆនរបស់ជីវិតនឹងត្រូវបំផ្លាញជាមិនខាន។ ដូច្នេះគាត់ក៏យល់ព្រមជួយពួកទេវតា។

នៅពេលនោះ ពួកអសុរាក៏កំពុងតែឈ្លោះគ្នា ដណ្តើមផឹកទឹកអម្រឹតមុន។ **ព្រះវិស្ណុ**ប្រែកាយជាស្រីស្អាតម្នាក់ មានឈ្មោះថា **មហិនី**។ មានសម្បុរខ្មៅភ្លឺ កាយស្រឡូន និងទាក់ទាញជាខ្លាំង។ នៅពេលដែល**មហិនី**ចូលទៅដល់ក្នុងវាំងរបស់ពួកទាណព ពួកទាណពមិនទាន់ផឹកអម្រឹតនៅឡើយ។ ដំណើររបស់នាង ស្នាមញញឹមរបស់នាង កែវភ្នែករបស់នាង បានធ្វើឲ្យពួកទាណពឈ្លក់វង្វេង ពួកគេរវល់គិតតែអំពីនាង ក៏ទុកអម្រឹតចោល។

ពួកអសុរាក៏សួរនាងថា៖ "ស្រីស្អាត នាងជានរណា? នាងមកពីណា? ប្រាប់ពួកយើងមក នាងជាកូននរណា។ នាងស្អាតណាស់។ នាងមកទីនេះចំជាឱកាសល្អមែន។ ឥលូវនេះពួកអសុរាយើង ពិតមែនតែមានឪពុកតែមួយមែន តែពួកយើងកំពុងឈ្លោះគ្នាដណ្តើមទឹកអម្រឹត។ យើងចង់ឲ្យនាងជួយចែកទឹកអម្រឹតដល់ពួកយើង ដូច្នេះពួកយើងនឹងមិនឈ្លោះគ្នាទៀតទេ"។

**នាងមោហិនី** បានតបថា៖ "តើបុគ្គលខ្ពង់ខ្ពស់ដូចជាអស់លោក អាចទុកចិត្តនឹងស្ត្រីចូលចិត្តសប្បាយដូចខ្ញុំយ៉ាងដូចម្តេចទៅ? មែនហើយគ្មានបណ្ឌិតណា ដែលធ្វើបែបនេះទេ"។ ដោយពាក្យរំញោកបែបនេះ នាងបានធ្វើឲ្យពួកអសុរា កាន់តែទុកចិត្តនាងថែមទៀត។ ពួកគេបានសើចក្អាកក្អាយ ដោយដៃកាន់ទឹកអម្រឹតទៅឲ្យនាង។

ដោយទទួលយកទឹកអម្រឹតបានហើយ **នាងមោហិនី** និយាយដោយសំដីផ្អែមល្ហែមថា៖ "អ្នកត្រូវយល់ព្រមតាមអ្វីដែលនាងខ្ញុំសម្រេចឲ្យធ្វើ ត្រូវក៏ដោយខុសក៏ដោយ បែបនេះ

ទើបខ្ញុំយល់ព្រមចែកទឹកអម្រឹតឲ្យ។ ពួកអសុរា ប្រាជ្ញារបស់ពួកគេងងឹតស្លុប ដោយសារតែសម្រស់របស់នាង មិនបានពិចារណាលើសំដីរបស់នាងអ្វីបន្តិច ក៏យល់ព្រមនឹងលក្ខខណ្ឌរបស់នាង។

នាងនិយាយថា ពួកទេវតានឹងត្រូវអញ្ជើញ ដើម្បីមកបង្ហាញថា ទាណពខ្លាំងពូកែមែន បង្ហាញថា ពួកទាណពមានកិត្តិយស និងស្រឡាញ់យុត្តិធម៌។ បន្ទាប់ពីរួញរាចិត្តបន្តិចមក **កាលកេតុ**ក៏យល់ព្រម ហើយពួកទាណពក៏អញ្ជើញពួកទេវតា។

ក្នុងនាមជាអ្នកអធិថិសត្ការ **មហិនី**ក៏សុំ**កាលកេតុ** យកអម្រឹតទៅចែកចាយដល់ភ្ញៀវដែលជាពួកទេវតា។ **កាលកេតុ**ក៏យល់ព្រមដោយគ្មានការសង្ស័យ។

**ទាណព ស្វរភានុ** សង្ស័យជាកលល្បិច ក៏បន្លំខ្លួនជាពួកទេវតា រួចចូលរួមក្នុងចំណោមពួកទេវតា។ **មហិនី**មិនដឹង ក៏ចែកទឹកអម្រឹតទៅឲ្យគាត់។ តែ**ទេវតា ចន្ទ្រាទេវ** ដឹងទាន់ ក៏ប្រាប់រឿងនេះដល់**មោហិនី** **មោហិនី**ក៏កាឡាជា**ព្រះវិស្ណុ**វិញ។ **ព្រះវិស្ណុ**ខឹង ក៏កាត់**ស្វរភានុ**ដាច់ជាពីរ។ នៅពេលដែល**ស្វរភានុ** ត្រូវបាន**ព្រះវិស្ណុ**សម្លាប់ សូម្បីតែអម្រឹត និងសំជីវិនមន្ត្រក៏មិនអាចជួយស្រោចស្រង់ជីវិតគាត់បានដែរ។ **ស្វរភានុ**ត្រូវបានកាត់ជាពីរកង់ ក្បាល និងខ្លួន។ ក្បាលក៏ក្លាយជារាហូ និងខ្លួនក្លាយជា កេតុ។ ដោយព្រះចន្ទជាអ្នកបកអាក្រាតកលល្បិចរបស់**ស្វរភានុ** រាហូ និងកេតុក្លាយជាសត្រូវរបស់ចន្ទ្រាទេវជារៀងរហូតមក។

ពួកទាណពដឹងថា**នាងមោហិនី** តាមពិតជា**ព្រះវិស្ណុ**។ **កាលកេតុ**ភ័យព្រួយ ពេលដឹងថាអម្រឹតអស់រលីងពីថូរទៅហើយ។ អម្រឹតទាំងអស់ ត្រូវពួកទេវតាផឹកអស់ហើយ។ **កាលកេតុ**ក្តៅក្រហាយ ក៏ប្រញាប់ទៅសម្លាប់**ព្រះវិស្ណុ**។ តែ**ព្រះវិស្ណុ**គេចខ្លួន។ នៅចុងបញ្ចប់ **កាលកេតុ** និងបក្សពួក ដឹងខ្លួនថា ចាញ់បោកគេម្តងទៀត ហើយពេលនេះច្បាស់ជាចាញ់សង្គ្រាមមិនខាន។

**សុក្រឆរ្យៈ**ក្តៅក្រហាយជាខ្លាំង។ គាត់ប្រកាសថា នរណាដែលធ្លាក់ក្នុងសំណាញ់សម្រស់របស់ស្ត្រី មិនអាចធ្វើអ្វីបានសម្រេចទេក្នុងជីវិត។

[1] អានថា ធន់ ន្វាន់ តៈ រី។

**ធន្វន្តរី** ជាគ្រូពេទ្យឥណ្ឌាសម័យបុរាណ និងជាគ្រូពេទ្យវះកាត់ដំបូងបង្អស់ម្នាក់លើលោក។ តាមប្រពៃណីហិន្ទូ គាត់ត្រូវបានគេចាត់ទុកថា ជាអ្នកបង្កើតអាយុរវេទ។ គាត់ពូកែខាងប្រើរុក្ខជាតិឱសថ ហើយជាអ្នករកឃើញលក្ខណៈអង់ទីសិបទិច របស់រមៀត និងលក្ខណៈរបស់អំបិល ដែលអាចប្រើសម្រាប់រក្សាសាច់ (ដូចជាប្រើអំបិលប្រលាក់ត្រី..) ដែលគាត់បានយកមកប្រើ ក្នុងការព្យាបាលរបស់គាត់។

ការវះកាត់របស់គាត់ទាំងអស់ ធ្វើទៅដោយគ្មានប្រើថ្នាំស្ពឹកនោះទេ តែទោះជាយ៉ាងណា វិធីសាស្ត្ររបស់គាត់ ត្រូវបានគេកត់ត្រាមកថា ទទួលបានជោគជ័យភាគច្រើន។

*សូមអភ័យទោសទុកជាមុន ចំពោះកំហុសឆ្គងនានាក្នុងអត្ថបទមួយនេះ*

*ជាពិសេសកំហុសអក្ខរាវិរុទ្ធ ព្រោះសង្កេតឃើញថា ឈ្មោះតួអង្គសុទ្ធតែពាក្យបែបបាលី បូសំស្ក្រឹត ដែលអាចនាំឲ្យមានកំហុសឆ្គងមិនខាន។*

*សូមអរគុណ!!!!*